ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...សហវ...

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១១

## គោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម

**កម្មវត្ថុ:** ករណីសំណើសុំទូទាត់ជម្រះបញ្ជីថវិកាបដិភាគដែលបានបើកផ្តល់ជូនមុន ជំហានទី២ ចំនួន ៣០.០០០ដុល្លារ សម្រាប់គាំទ្រគម្រោងកែលម្អការអភិវឌ្ឍ និងការគ្រប់គ្រងអាងស្តុកទឹកសម្រាប់កសិកម្ម ដំណាក់កាលទី៣។

**យោង:** លិខិតលេខ ៧២៨ ធទឧ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹក និង ឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមឯកភាពលើសំណើសុំទូទាត់ជម្រះបញ្ជីចំពោះថវិកាដែលបានបើកផ្តល់ជូនមុនសម្រាប់ចំណាយលើដំណើរការអនុវត្តគម្រោងកែលម្អការអភិវឌ្ឍ និងការគ្រប់គ្រងអាងស្តុកទឹកសម្រាប់កសិកម្ម ដំណាក់កាលទី៣ ត្រឹមទឹកប្រាក់ដែលផ្តល់ជូនចំនួន ៣០.០០០ ដុល្លារ (សាមសិបពាន់ដុល្លារអាមេរិកគត់) តាមរយៈអាណត្តិបើកប្រាក់លេខ ០០៤០ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១១ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការ តាមការគួរ។
សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**

- អគ្គនាយកដ្ឋានរតនាគារជាតិ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798